01454899

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Preliminaire

ឯកសារ D343/4

***តាមនាមប្រជាពលរដ្ឋខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃ កម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៦)

ចំពោះមុខ: **ចៅក្រម ប្រាក់ គីមសាន ជាប្រធាន**
**ចៅក្រម Olivier BEAUVALLET**
**ចៅក្រម ន៉ីយ ថុល**
**ចៅក្រម Kang Jin BAIK**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 04 / 2017
ម៉ោង (Time/Heure): 09:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ:កែសម្រួល**

**សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទី៥របស់ [redacted]**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី [redacted]**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

01454900



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ [redacted]" ដែលសហមេធាវីការពារក្តីរបស់ [redacted] (ហៅថា "ម្ចាស់បណ្តឹងឧទ្ធរណ៍" និង "មេធាវីការពារក្តី") បានដាក់នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ ("បណ្តឹងឧទ្ធរណ៍")[1]។

## I. សេចក្តីផ្តើម

1. បណ្តឹងឧទ្ធរណ៍នេះពាក់ព័ន្ធនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") ដែលបានចេញនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ដែលបានបដិសេធផ្នែកខ្លះនៃសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ("ដីកាដែលត្រូវបានជំទាស់")[2]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ដោយចោទប្រកាន់ម្ចាស់បណ្តឹងឧទ្ធរណ៍ថា មានការជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មមួយចំនួន និងស្នើសុំឱ្យធ្វើការចោទប្រកាន់ទៅលើរូបគាត់ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"[3]។

3. នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ ស.ច.ស.អ បានជូនដំណឹងដល់ម្ចាស់បណ្តឹងឧទ្ធរណ៍អំពីបទចោទប្រកាន់ទាំងនោះ និងបានអនុញ្ញាតឱ្យមេធាវីការពារក្តីមានសិទ្ធិចូលមើលសំណុំរឿងបាន[4]។

4. នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ស.ច.ស.អ បានចេញអនុស្សរណៈមួយច្បាប់ដែលបង្គាប់ឱ្យមន្ត្រីស៊ើបអង្កេតទាំងអស់ *ក្នុងចំណោមចំណុចផ្សេងៗ* កម្រិតការសន្ទនាវាយតម្លៃរបស់ខ្លួនទៅលើសាក្សីសក្ខីភាព ឬដើមបណ្តឹងរដ្ឋប្បវេណី ត្រឹមតែការបញ្ជាក់អំពីអត្តសញ្ញាណ និងអាស័យដ្ឋាន

---

[1] បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ [redacted] ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ ឯកសារ D343/2។

[2] ដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ [redacted] ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ D311/1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[4] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ [redacted] ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D242។



PRE-TRIAL CHAMBER E.C.C.C

របស់បុគ្គលរូបនោះ ព្រមទាំងសមត្ថភាព និងឆន្ទៈរបស់គាត់ក្នុងការផ្តល់ព័ត៌មាននានាស្តីពីប្រធានបទនៃការស្តាប់ចម្លើយដែលខ្លួនចង់បាន ("អនុស្សរណៈ") [5]។

5. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើសុំមួយនៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") "ដោយអនុលោមតាមវិធាន ២១ វិធាន ៥៥(១០) និងវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុង" ស្នើសុំឱ្យ ស.ច.ស (១) ស្វែងរក និងដាក់ចូលទៅក្នុងសំណុំរឿងនូវកំណត់ហេតុដែលបាត់ ឈ្មោះរបស់សាក្សីដែលមិនបានកំណត់អត្តសញ្ញាណ និងចំណុចលម្អិតនៃការសន្ទនាវាយតម្លៃរបស់ខ្លួន ព្រមទាំងប្រភពនានានៃការអះអាងរបស់មន្ត្រីស៊ើបអង្កេត ឬ (២) ក្នុងករណីដែលព័ត៌មានដូចបានស្នើសុំខាងលើមិនមាននោះ ស្នើសុំឱ្យបញ្ជាក់ដូចគ្នា និងដាក់ទៅក្នុងសំណុំរឿងនូវកំណត់ត្រារបស់អ្នកស៊ើបអង្កេត អ្នកបកប្រែភាសា អ្នកវិភាគ អ្នកប្រតិចារឹក ឬអ្នកដទៃទៀតដែលមានវត្តមាននៅក្នុងបេសកកម្មនេះ ("សំណើលើកទីដប់") [6]។

6. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ស.ច.ស.អ បានចេញដីកាសម្រេចដែលត្រូវបានជំទាស់ ដោយជូនដំណឹងដល់មេធាវីការពារក្តីថា សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់ត្រូវបានយល់ព្រមតាមត្រង់ផ្នែកខ្លះ និងបដិសេធផ្នែកសេសសល់ពីនេះ[7]។

7. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានជូនដំណឹងដល់ភាគីទាំងអស់ថា ស.ច.ស "យល់ឃើញថា កិច្ចស៊ើបសួរប្រឆាំង [redacted] ត្រូវបានបញ្ចប់ហើយ [8] និងបានចេញដីកាបង្គាប់ "ឱ្យធ្វើការបំបែកសំណុំរឿង [redacted] ចេញពីសំណុំរឿង ០០៤"[9]។

8. នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៦ មេធាវីការពារក្តីបានជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដែលត្រូវបានជំទាស់នេះ[10]។ នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៧ មេធាវីការពារក្តីបានដាក់

---

[5] អនុស្សរណៈពី ស.ច.ស.អ ផ្ញើជូនអ្នកស៊ើបអង្កេតទាំងអស់ពាក់ព័ន្ធនឹង "ការណែនាំស្តីពីការវាយតម្លៃដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដទៃទៀត និងស្តីពីកំណត់ហេតុជាលាយលក្ខណ៍អក្សរ" ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D269 ("អនុស្សរណៈ") កថាខណ្ឌ ១។

[6] សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D311។

[7] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៥១-១៥២។

[8] សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង [redacted] ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ D334។

[9] ដីកាសម្រេចបំបែកសំណុំរឿង [redacted] ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ D334/1។

[10] ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ D343។

សំណើសុំដាក់បណ្ដឹងឧទ្ធរណ៍នេះជាភាសាអង់គ្លេសសិន ហើយការបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយ (“សំណើរបស់មេធាវីការពារក្ដីលើផ្នែកភាសា”)[11]។ បណ្ដឹងឧទ្ធរណ៍នេះត្រូវបានដាក់តែជាភាសាអង់គ្លេសសិន នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ ហើយបណ្ដឹងឧទ្ធរណ៍ជាភាសាខ្មែរត្រូវបានដាក់នៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៧។

9. នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស.ព.អ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍នេះ (“ចម្លើយតប”)[12]។ មេធាវីការពារក្ដីពុំបានដាក់ការឆ្លើយតបណាមួយទៅនឹងចម្លើយតបនេះទេ។

## III. ភាពអាចទទួលយកបាន

10. ម្ចាស់បណ្ដឹងឧទ្ធរណ៍បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ ស្របតាមពេលវេលាកំណត់ដែលមានចែងក្នុងវិធាន ៧៥(១) នៃវិធានផ្ទៃក្នុង។ បន្ថែមលើនេះទៀត កាលពីថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៧ ក្រោយពីបានពិចារណាថា (១) សំណើរបស់មេធាវីការពារក្ដីលើផ្នែកភាសានេះបានផ្ដល់មូលហេតុអាចឱ្យទទួលយកបាន (២) ស.ព.អ មិនបានធ្វើការជំទាស់ណាមួយនោះទេ និង (៣) សំណៅជាភាសាអង់គ្លេសនៃបណ្ដឹងឧទ្ធរណ៍នេះ ត្រូវបានដាក់ភ្លាមៗនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧ អង្គបុរេជំនុំជម្រះបានសម្រេចទទួលយកសំណើរបស់មេធាវីការពារក្ដីលើផ្នែកភាសា និងបានអនុញ្ញាតឱ្យធ្វើការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍នេះ។

11. អង្គបុរេជំនុំជម្រះយល់ស្របជាមួយម្ចាស់បណ្ដឹងឧទ្ធរណ៍ថា[13] បណ្ដឹងឧទ្ធរណ៍នេះអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ខ) ដែលចែងនៅត្រង់ផ្នែកពាក់ព័ន្ធថា៖

**វិធាន ៧៤៖ មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ**

> (៣) ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបាន [...]

---

[11] សំណើសុំការអនុញ្ញាតដើម្បីដាក់ជាភាសាអង់គ្លេសជាមុនខ្លួនបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទី ១០ របស់ [redacted] ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៧ ឯកសារ D343/1។

[12] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទី ១០ របស់គាត់ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ D343/3។

[13] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៣-១៥។ *សូមមើលផងដែរ* សំណើទីដប់ កថាខណ្ឌ ១។

(ខ) ការបដិសេធពាក្យសុំឱ្យមានកិច្ចស៊ើបសួរណាមួយ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។ [...]

## IV. បទដ្ឋាននៃការពិនិត្យឡើងវិញ

12. អនុលោមតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអាចត្រូវបានបដិសេធចោល ក្នុងករណីដែលដីកាសម្រេចទាំងនោះ (ក) បានផ្អែកលើកំហុសអង្គច្បាប់ ដែលនាំឱ្យដីកាសម្រេចនោះគ្មានសុពលភាព (ខ) បានផ្អែកលើកំហុសអង្គហេតុ ដែលនាំឱ្យមានការរំលោភលើភាពយុត្តិធម៌ ឬ (គ) មានភាពអយុត្តិធម៌យ៉ាងខ្លាំង ឬមិនសមហេតុផលទាល់តែសោះ ដែលជាការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់ចៅក្រម[14]។ អង្គបុរេជំនុំជម្រះសូមរម្លឹកឡើងវិញបន្ថែមទៀតថា ដោយគិតទៅដល់ភារកិច្ចទូទៅ និងការយល់ដឹងលើសំណុំរឿងរបស់ខ្លួន ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ គឺជាដីកាសម្រេចដែលបានធ្វើឡើងតាមឆន្ទានុសិទ្ធិ ដោយសារសហចៅក្រមស៊ើបអង្កេត គឺជាអ្នកដែលមានលក្ខណៈសម្បត្តិប្រសើរបំផុតក្នុងការវាយតម្លៃថាតើសំណើសុំនោះពិតជាអាចនាំឱ្យឈានទៅដល់ការស្វែងរកការពិតដែរឬយ៉ាងណានោះ[15]។ ដើម្បីឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះ កំហុសនោះត្រូវតែមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិ ដែលជាហេតុនាំឱ្យភាគីប្ដឹងឧទ្ធរណ៍[16]។

## V. អង្គសេចក្ដី

13. ក្រោយពីពិនិត្យមើលឡើងវិញលើបណ្ដឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះពិចារណាឃើញថា កិច្ចស៊ើបសួរដែលត្រូវបានស្នើសុំឱ្យបំពេញពុំចាំបាច់ធ្វើឡើងនោះទេ។ ចៅក្រមនៃអង្គបុរេជំនុំជម្រះសូមដាក់ភ្ជាប់មតិយោបល់។

---

[14] *សូមមើលជា ឧ.* សំណុំរឿង ០០៤/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤") (អបជ២៤)៖ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទីប្រាំរបស់ [redacted] សុំឱ្យបំពេញកិច្ចស៊ើបសួរ (អបជ២៤) ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ D260/1/1/3 ("សេចក្ដីពិចារណាលើសំណើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីប្រាំ") កថាខណ្ឌ ១៥។

[15] សេចក្ដីពិចារណាលើសំណើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីប្រាំ កថាខណ្ឌ ១៦។

[16] *ដូចខាងលើ*។

សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៦)

ឯកសារលេខ D343/4

**យោងតាមសំអាងហេតុខាងលើនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

- **ទទួលយក**បណ្តឹងឧទ្ធរណ៍តាមទម្រង់ច្បាប់។

- **ច្រានចោល**បណ្តឹងឧទ្ធរណ៍លើអង្គសេចក្តី។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះពុំបើកផ្លូវឱ្យប្តឹងតវ៉ានោះទេ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី បានដាក់ភ្ជាប់មតិយោបល់។

ចៅក្រម Olivier BEAUVALLET និងចៅក្រម Kang Jin BAIK បានដាក់ភ្ជាប់មតិយោបល់។

**មតិយោបល់ចៅក្រម ប្រាក់ គីម សាន ចៅក្រម ន័យ ចុល និងចៅក្រម ហួត វុទ្ធី**

14. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ (“អ.វ.ត.ក”) នឹងបង្ហាញអំពីមតិយោបល់របស់ខ្លួនទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក [redacted] ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ [redacted]។

15. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា អ.វ.ត.ក ត្រូវបានបង្កើតឡើងតាម កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (កិច្ចព្រមព្រៀង), ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ច្បាប់ អ.វ.ត.ក) និងអនុវត្តវិធានផ្ទៃក្នុង។

16. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការពិសេសមួយដែលអនុវត្តនីតិវិធីនៃការចោទប្រកាន់ និងការស៊ើបសួរ ខុសពីតុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា។ ការចោទប្រកាន់ និង ការស៊ើបសួររបស់តុលាការថ្នាក់ជាតិនៃប្រទេសកម្ពុជា គឺធ្វើឡើងតែលើអង្គហេតុទេ មានន័យថា មិនមែនជាការចោទប្រកាន់ និងការស៊ើបសួរលើបុគ្គលឡើយ[17]។ ផ្ទុយមកវិញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចោទប្រកាន់ និងការស៊ើបសួរ អាចធ្វើទៅបាន លុះត្រាបំពេញលក្ខខណ្ឌពីរ គឺ ទី១.***អង្គហេតុ*** “ឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុង អំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩” និង ទី២.***បុគ្គល*** “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម”[18]។

[17] មាត្រា ៤៤ និង ១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[18] មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, មាត្រា ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធាន ៥៣ នៃវិធានផ្ទៃក្នុង។

17. សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានខ្វែងយោបល់គ្នាចំពោះការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៤ នេះ ដោយសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣។ រីឯសហព្រះរាជអាជ្ញាជាតិបានបដិសេធចោលនូវដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ ផ្អែកលើមូលដ្ឋាន "ជនសង្ស័យទាំងនេះ មិនមែនជាមេដឹកនាំជាន់ខ្ពស់ និង/ឬ អ្នកទទួលខុសត្រូវខ្ពស់បំផុត"[19] ហើយចៅក្រមជាតិ និងអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ក៏បានខ្វែងយោបល់គ្នាចំពោះបញ្ហានេះដែរ ដោយចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ គាំទ្រទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាជាតិ[20]។

18. ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះធ្លាប់សម្រេចម្តងរួចហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនចាំបាច់ធ្វើកិច្ចស៊ើបសួរ ឬស៊ើបសួរបន្ថែមណាមួយ នៅក្នុងសំណុំរឿង ០០៤ ទៀតឡើយ។[21] ដូច្នេះមិនមានភាពចាំបាច់ណាមួយដែលតម្រូវឱ្យចៅក្រមជាតិធ្វើការពិចារណាទៅលើសំណើសុំ ឬពាក្យបណ្តឹងដែលមានកម្មវត្ថុដូចគ្នានេះទេ។

19. តាមការយល់ឃើញខាងលើនេះ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះសម្រេចបដិសេធបណ្តឹងឧទ្ធរណ៍នេះ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ២៦ ខែមេសា ឆ្នាំ២០១៧**

**ប្រធាន ប្រាក់ គីមសាន** | **ចៅក្រម ន័យ ថុល** | **ចៅក្រម ហួត វុទ្ធី**

---

[19] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំឱ្យដាក់ឯកសារពិស្តារបន្ថែមរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៩ និងសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០៩ កថាខណ្ឌទី ៨៦ (ក)។

[20] យោបល់របស់ចៅក្រម ប្រាក់ គីមសាន, ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ចុះថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០០៩ "[redacted] មិនមែនជា មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"។

[21] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើលើកទីប្រាំរបស់[redacted] ស្នើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌទី៣០ ឯកសារលេខD260/1/1/3។

# មតិយោបល់លើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ដោយចៅក្រម BEAUVALLET និងចៅក្រម BAIK ("ចៅក្រមដែលបានចុះហត្ថលេខា")

## ក. សំណើ

***បណ្តឹងឧទ្ធរណ៍***

20. មេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (១) ច្រានចោលផ្នែកនានានៃដីកាសម្រេចដែលត្រូវបានជំទាស់នេះ ដែលបានរងព្យសនកម្មដោយសារកំហុសអង្គច្បាប់ដែលបានចោទប្រកាន់ (២) បង្គាប់ឱ្យ ស.ច.ស.អ ដាក់ចូលទៅក្នុងសំណុំរឿងនូវកំណត់ត្រារបស់អ្នកស៊ើបអង្កេត អ្នកបកប្រែ អ្នកវិភាគ អ្នកធ្វើប្រតិចារឹក ឬបុគ្គលផ្សេងទៀតដែលមានវត្តមាននៅក្នុងអំឡុងពេលនៃ "ការស្តាប់ចម្លើយ" ពាក់ព័ន្ធ ដែលបានលើកឡើងនៅក្នុងឧបសម្ព័ន្ធ ក និងឧបសម្ព័ន្ធ ខ នៃសំណើលើកទីដប់ ដែល ស.ច.ស.អ បានបញ្ជាក់ថាពុំមានកំណត់នៃការស្តាប់ចម្លើយ ឬខ្សែអាត់សម្លេងនោះ[22]។ មេធាវីការពារក្តីបានលើកឡើងនូវមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ចំនួនពីរ ដោយជំទាស់តវ៉ាថា ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយ (១) ការកំណត់អនុស្សរណៈនេះថាជា "បទដ្ឋានអនុវត្តដ៏ប្រសើរបំផុត" ដែល "ពុំបង្កើតជាកាតព្វកិច្ចតាមផ្លូវច្បាប់នោះឡើយ"[23] និង (២) ការបដិសេធសំណើរបស់មេធាវីការពារក្តីសុំឱ្យដាក់ចូលទៅក្នុងសំណុំរឿងនូវកំណត់ត្រារបស់អ្នកស៊ើបអង្កេត អ្នកបកប្រែ អ្នកវិភាគ អ្នកធ្វើប្រតិចារឹក ឬបុគ្គលផ្សេងទៀតដែលមានវត្តមាននៅក្នុងអំឡុងពេលនៃកិច្ចសន្ទនាវាយតម្លៃ ("សំណើសុំឱ្យផ្តល់កំណត់ត្រាផ្សេងៗ") ដោយលើកឡើងថា កំណត់ត្រាទាំងនោះគឺជា "លទ្ធផលការងារផ្ទៃក្នុង" និងពុំតម្រូវឱ្យបញ្ចេញឱ្យដឹងឡើយ[24]។

21. នៅក្នុងមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីលើកឡើងថា ការកំណត់អនុស្សរណៈថាជា "បទដ្ឋានអនុវត្តដ៏ប្រសើរបំផុត" ដែល "ពុំបង្កើតជាកាតព្វកិច្ចតាមផ្លូវច្បាប់នោះ" គឺ "មិនស្របទៅ

---

[22] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣។

[23] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥-៣៣ *ដោយយោងទៅ*លើដីកាសម្រេចដែលត្រូវបានជំទាស់ត្រង់កថាខណ្ឌ ១៥ និងយើងទៅអនុស្សរណៈនេះត្រង់កថាខណ្ឌ ១ និង ២។

[24] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤-៤១។ *សូមមើលផងដែរ* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣ *ដែលយោងទៅ*លើដីកាសម្រេចដែលត្រូវបានជំទាស់ត្រង់កថាខណ្ឌ ១៨។

នឹងច្បាប់នីតិវិធីនោះទេ"[25]។ យោងតាមមេធាវីការពារក្តី "អនុស្សរណៈនេះត្រូវបានចាត់ទុកថាជាមធ្យោបាយមួយដែល ស.ច.ស.អ អនុវត្តមុខងារត្រួតពិនិត្យរបស់គាត់ដូចមានចែងក្នុងវិធាន ៦២ នៃវិធានផ្ទៃក្នុង"[26] ហើយពាក្យពេចន៍នៅក្នុងអនុស្សរណៈនេះ "គឺជាការលើកឡើងយ៉ាងច្បាស់អំពីសេចក្តីបង្គាប់ចាំបាច់ត្រូវតែអនុវត្តតាមចាប់ពីថ្ងៃចេញអនុស្សរណៈនេះទៅ"[27]។ លើសពីនេះទៀត មេធាវីការពារក្តីបានជំទាស់តវ៉ាទៅនឹងការបកស្រាយរបស់ ស.ច.ស.អ និងការបកស្រាយរបស់អង្គបុរេជំនុំជម្រះទៅលើអនុស្សរណៈនេះថាជា "សេចក្តីណែនាំទៅតាមឆន្ទានុសិទ្ធិនោះ" គឺជាកំហុសអង្គច្បាប់មួយហើយ ដោយសារថា "ឆន្ទានុសិទ្ធិដែលបានលើកឡើងដោយអង្គជំនុំបុរេជំនុំជម្រះ គឺជាឆន្ទានុសិទ្ធិដែលមកជាប់ជាមួយនឹង ស.ច.ស.អ នៅក្នុងការចេញសេចក្តីណែនាំ ពុំមែនថាអ្នកស៊ើបអង្កេតមានឆន្ទានុសិទ្ធិក្នុងការអនុវត្តតាមសេចក្តីណែនាំទាំងនេះឡើយ"[28]។ បន្ថែមលើនេះទៀត មេធាវីការពារក្តីអះអាងថា "ពាក្យពេចន៍នៅក្នុងអនុស្សរណៈដែល ស.ច.ស.អ សម្រេចថា សេចក្តីណែនាំនៅក្នុងអនុស្សរណៈនេះត្រូវយកមកអនុវត្តតាម "*បន្ថែមលើ* នីតិវិធីនៅក្នុងវិធាន ៥៥(៧) នៃវិធានផ្ទៃក្នុង [...] ចង់លើកឡើងថា សេចក្តីណែនាំទាំងនេះត្រូវតែមានអានុភាពតាមផ្លូវច្បាប់"[29]។ ចុងក្រោយ មេធាវីការពារក្តីលើកឡើងថា ពាក្យពេចន៍នៅក្នុងអនុស្សរណៈនេះនាំឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍មានការរំពឹងដោយសមស្របថា សេចក្តីណែនាំទាំងនោះនឹងត្រូវអនុវត្តតាម ហើយ "ការផ្លាស់ប្តូរលក្ខណៈនៃនីតិវិធីនៅពេលបញ្ចប់កិច្ចស៊ើបសួរ គឺធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់មេធាវីការពារក្តីនៅក្នុងការវិភាគលើសំណុំរឿង និងលទ្ធភាពក្នុងការចូលរួមនៅក្នុងកិច្ចស៊ើបសួរ"[30]។ "ការបកស្រាយណាមួយផ្ទុយពីនេះ គឺជាការបំពានលក្ខខណ្ឌតម្រូវស្តីពីសច្ចភាពផ្លូវច្បាប់អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង"[31] និង "ហេតុដូច្នេះ ការធ្វើអន្តរាគមន៍របស់អង្គបុរេជំនុំ

---

[25] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥។

[26] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៦-២៧។

[27] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៨-២៩ *ដែលយោងទៅ*អនុស្សរណៈនេះត្រង់កថាខណ្ឌ ១-២។

[28] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០ *ដែលយើងទៅ*សំណុំរឿង ០០៤ (អបជ៣១), សាលដីកាលើសំណើរបស់ [redacted] សុំធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយដែលមិនមានខ្សែអាត់សម្លេង ឯកសារ D296/1/1/4 ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ កថាខណ្ឌ ២៥។

[29] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣១។

[30] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣២។

[31] *ដូចខាងលើ*។

ជម្រះ គឺជាការចាំបាច់ក្នុងការទប់ស្កាត់ការខូចខាតដែលមិនអាចជួសជុលបានចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ [redacted]"[32]។

22. នៅក្នុងមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីអះអាងថា សំអាងហេតុដែលបានប្រើប្រាស់នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ ដើម្បីគាំទ្រការច្រានចោលសំណើសុំកំណត់ត្រា "ការអះអាងជារួមថា វិធានការណាក៏ដោយដែលធ្វើឡើងមុនពេលមានកំណត់ហេតុ ត្រូវបានការពារដោយទ្រឹស្តីនៃ "លទ្ធផលការងារផ្ទៃក្នុង"[33] ហើយវិធីសាស្ត្រនេះ "(១) រារាំងមេធាវីការពារក្តីមិនឱ្យទទួលបានព័ត៌មានដែលអាចជួយដល់ការស្វែងយល់ និងតវ៉ាចំពោះភស្តុតាងរបស់សាក្សីជាក់លាក់ (២) រារាំងមេធាវីការពារក្តីមិនឱ្យពិនិត្យបន្ថែមលើករណីថាតើ កិច្ចសន្ទនាវាយតម្លៃធ្វើឡើងហួសពីការអនុញ្ញាត និង (៣) ប៉ះពាល់ដល់លទ្ធភាពរបស់មេធាវីការពារក្តីក្នុងការវាយតម្លៃលើបញ្ហានានាពាក់ព័ន្ធនឹងការធ្វើឱ្យប៉ះពាល់ដល់សាក្សី"[34]។ មេធាវីការពារក្តីសន្និដ្ឋានថា ជំហររបស់ ស.ច.ស.អ មានលក្ខណៈផ្ទុយពីយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងទៀតដែលយោងតាមយុត្តិសាស្ត្រទាំងនេះ "ទ្រឹស្តីនៃលទ្ធផលការងារផ្ទៃក្នុង [...] កម្រិតត្រឹមអ្វីដែលភាគី និងភ្នាក់ងាររបស់ភាគី បង្កើតឡើងប៉ុណ្ណោះ [វាពុំអាចយកទៅអនុវត្តចំពោះចម្លើយសាក្សីនោះទេ]"[35]។ យោងតាមមេធាវីការពារក្តី នៅក្នុងសំណុំរឿងបច្ចុប្បន្ន កិច្ចសន្ទនាក្រៅពីសំណួរវាយតម្លៃ គឺជា "ចម្លើយ" ហេតុដូច្នេះ មិនអាចធ្វើចំណាត់ប្រភេទថាជា "លទ្ធផលការងារ" ហើយត្រូវដាក់បង្ហាញ[36]។ មេធាវីការពារក្តីអះអាងបន្ថែមទៀតថា យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះដែលបានសំអាងដោយ ស.ច.ស.អ នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ ពុំបានផ្តល់ជូន ស.ច.ស.អ នូវ

---

[32] *ដូចខាងលើ*។

[33] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤។

[34] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤។

[35] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៥ ដល់ កថាខណ្ឌ ៣៨ ដកស្រង់រឿងក្តី *Eliézer Niyitegeka តទល់នឹង* តុលាការ ICTR-96-14-A "សាលដីកា" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៣៤ ដល់ កថាខណ្ឌ ៣៥។ នៅក្នុងរឿងក្តី *Matter of El Sayed* CH/AC/2011/01 "សាលដីកាលើបណ្តឹងឧទ្ធរណ៍មួយផ្នែករបស់លោក El Sayed ប្រឆាំងនឹងសេចក្តីសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១" អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៧៣ កថាខណ្ឌ ៨៥។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Alex Tamba Brima, Brima Bazzy Kamara and Santigie Borbor Kani* SCSL-04-16-T "សេចក្តីសម្រេចលើពាក្យសុំរួមរបស់មេធាវីការពារក្តីលើការដាក់បង្ហាញចម្លើយសាក្សីដើមទាំងអស់ កំណត់ត្រាកិច្ចសម្ភាសន៍ និងកំណត់ត្រារបស់អ្នកស៊ើបអង្កេតអនុលោមតាមវិធាន ៦៦ និង/ឬ វិធាន ៦៨"។

[36] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩។

"អំណាចឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិហាមឃាត់ជាទូទៅចំពោះការបង្ហាញព័ត៌មានដែលគួរ និងត្រូវចាត់ទុកជាផ្នែកមួយនៃកំណត់ហេតុដោយពុំមានការពិនិត្យឱ្យបានត្រឹមត្រូវនោះទេ"[37]។ យោងតាមមេធាវីការពារក្តី ព័ត៌មានដែលបានស្នើសុំនៅក្នុងសំណើសុំលើកទីដប់ "ពាក់ព័ន្ធជាក់លាក់ទៅនឹង ភស្តុតាងសំខាន់ ហើយការបង្ហាញព័ត៌មាននេះមានប្រយោជន៍ដល់ការបញ្ជាក់ការពិតនៅក្នុងការស៊ើបអង្កេត និងអាចនាំឱ្យមានភស្តុតាងដោះបន្ទុក"[38]។

*ចម្លើយតប*

23. នៅក្នុងចម្លើយតប ស.ព.អ ស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលបណ្តឹងឧទ្ធរណ៍[39]។ ចំពោះមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ ស.ព.អ សន្និដ្ឋានថា ម្ចាស់បណ្តឹងឧទ្ធរណ៍ "ធ្វើមិនដឹងមិនឮចំពោះអង្គហេតុដែល [ស.ច.ស] មានឆន្ទានុសិទ្ធិដ៏ទូលំទូលាយក្នុងការដឹកនាំអនុវត្តកិច្ចស៊ើបសួររបស់ខ្លួន"[40] ហើយ "គោលការណ៍ណែនាំដែល ស.ច.ស.អ ផ្តល់ដល់បុគ្គលិករបស់គាត់ស្តីពីការដឹកនាំអនុវត្តចំពោះការស្តាប់ចម្លើយនោះ មិនបានប្រគល់ឱ្យ [redacted] នូវសិទ្ធិក្នុងការទទួលបានកិច្ចស៊ើបសួរដែលអនុវត្តឡើងតាមរបៀបណាមួយជាក់លាក់នោះទេ"[41]។ ពាក់ព័ន្ធនឹងមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ ស.ព.អ អះអាងថា ម្ចាស់បណ្តឹងឧទ្ធរណ៍ខកខានមិនបានបង្ហាញថាតើការច្រានចោលសំណើសុំកំណត់ត្រាមានអានុភាពប៉ះពាល់លើរឿងក្តីរបស់គាត់ដោយរបៀបណានោះឡើយ[42]។ យោងតាម ស.ព.អ ដីកាសម្រេចដែលត្រូវបានជំទាស់បង្ហាញថា "ការសន្ទនារបស់អ្នកស៊ើបអង្កេតជាមួយសាក្សីសក្តានុពលត្រូវបានកត់ត្រាក្នុងរបាយការណ៍នៃសកម្មភាពស៊ើបអង្កេត WRIAs"[43] ហើយម្ចាស់បណ្តឹងឧទ្ធរណ៍ "មិនបានបង្ហាញឱ្យឃើញពីហេតុផលណាមួយដែលនាំឱ្យជឿបានថាសេចក្តីសង្ខេបនៃការសន្ទនាពេលសួរដែលមានផ្ទុកនៅក្នុង WRIAs មិនពេញលេញ ឬមិនត្រឹមត្រូវនោះទេ"[44]។ ម្យ៉ាងវិញទៀត ស.ព.អ សន្និដ្ឋានថា ការលើកឡើងរបស់ ស.ច.ស.អ នៅក្នុងដីកា

37 បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤០។

38 *ដូចខាងលើ*។

39 ចម្លើយតប កថាខណ្ឌ ៥។

40 ចម្លើយតប កថាខណ្ឌ ២ *ដែលយោងលើ* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤ ដល់ កថាខណ្ឌ ៣៣។

41 ចម្លើយតប កថាខណ្ឌ ២។

42 ចម្លើយតប កថាខណ្ឌ ៤ *ដែលយោងលើ* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤ កថាខណ្ឌ ៣៤ ដល់ កថាខណ្ឌ ៤១។

43 ចម្លើយតប កថាខណ្ឌ ៤ *ដែលយោងលើ* ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៦។

44 ចម្លើយតប កថាខណ្ឌ ៤។

សម្រេចដែលត្រូវបានជំទាស់ថា គាត់នឹងមិនប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងសេចក្តីសង្ខេបកិច្ចសន្ទនាវាយតម្លៃក្នុងគោលបំណងដាក់បន្ទុក គឺជា "ការការពារបន្ថែមមួយទៀតប្រឆាំងនឹងការធ្វើឱ្យខូចចំពោះសិទ្ធិដែរ"[45]។

## ខ. កិច្ចពិភាក្សា

24. ជាចំណុចដំបូង ចៅក្រមដែលចុះហត្ថលេខាកត់សម្គាល់ឃើញថា វិសាលភាពនៃបណ្តឹងឧទ្ធរណ៍ត្រូវបានកម្រិតត្រឹមឧបសម្ព័ន្ធ ក និងឧបសម្ព័ន្ធ ខ នៃសំណើសុំលើកទីដប់[46]។ នៅពេលនេះ ចៅក្រមដែលចុះហត្ថលេខាត្រូវពិចារណាទៅលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ម្តងមួយៗ។

### ១. សេចក្តីណែនាំដែលមាននៅក្នុងអនុស្សរណៈ

25. នៅក្នុងសំណើសុំលើកទីដប់ ពាក់ព័ន្ធនឹងឧបសម្ព័ន្ធ ក និងឧបសម្ព័ន្ធ ខ មេធាវីការពារក្តីស្នើសុំ ក.ស.ច.ស ឱ្យ i) កំណត់ទីតាំង និងដាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងខ្សែអាត់សម្លេងដែលត្រូវគ្នាទាំងនោះ នៅក្នុងសំណុំរឿង ហើយកំណត់អត្តសញ្ញាណបុគ្គលដែលបានលើកឡើង ឬ ii) ក្នុងករណីព័ត៌មានស្នើសុំខាងលើពុំមាន បញ្ជាក់ដូចគ្នា និងដាក់ក្នុងសំណុំរឿងនូវកំណត់ត្រាដែលបានធ្វើឡើងដោយអ្នកស៊ើបអង្កេត អ្នកបកប្រែ អ្នកវិភាគ អ្នកធ្វើប្រតិចារឹក ឬ បុគ្គលផ្សេងទៀតដែលមានវត្តមាននៅក្នុងអំឡុងពេលបំពេញបេសកកម្មដែលបានរាយការណ៍ទាំងនោះ។ នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ ស.ច.ស.អ បញ្ជាក់ថា ពុំមានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងខ្សែអាត់សម្លេងដែលត្រូវគ្នាទេ បានបញ្ជាក់អត្តសញ្ញាណបុគ្គលដែលបានស្នើសុំ ព្រមទាំងច្រានចោលសំណើសុំដាក់កំណត់ត្រាទាំងនោះនៅក្នុងសំណុំរឿង។

26. នៅក្នុងបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីស្នើសុំច្រានចោលផ្នែកខ្លះនៃដីកាសម្រេចដែលត្រូវបានជំទាស់ដែលតាមការអះអាងរបស់មេធាវីថាបានទទួលរងការប៉ះពាល់ដោយសារតែកំហុសអង្គច្បាប់ "នៅក្នុងការកំណត់ថា អនុស្សរណៈជា "បទដ្ឋានដ៏ប្រសើរបំផុត" ដែល "ពុំបង្កើតកាតព្វកិច្ចតាមផ្លូវច្បាប់នោះឡើយ"[47]។ ការពិនិត្យមើលដីកាសម្រេចដែលត្រូវបានជំទាស់បង្ហាញថា ការកំណត់ដោយ ស.ច.ស.អ នៅក្នុងអនុស្សរណៈថាជា "ការអនុវត្តដ៏ប្រសើរបំផុត" មានគោល

[45] *ដូចខាងលើ*។

[46] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៣។

[47] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥ *ដែលយោងលើ* ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៥។

បំណងតែមួយគត់គឺដើម្បីពន្យល់ថា "អនុស្សរណៈពុំបង្កើតកាតព្វកិច្ចផ្លូវច្បាប់សម្រាប់អ្នកស៊ើបអង្កេត ឬ *ប៉ះពាល់សុពលភាពនីតិវិធីនៃកិច្ចស៊ើបសួរនោះឡើយ*"[48]។ ហេតុដូច្នេះ កិច្ចពិភាក្សាអំពីអានុភាពផ្លូវច្បាប់នៃអនុស្សរណៈ ពុំមែនជា*សំអាងហេតុនៃសេចក្ដីសម្រេចពីមុន* *(ratio decidendi)* នៅក្នុងការសម្រេចថាតើគួរ ឬមិនគួរយល់ព្រមតាមសំណើសុំរបស់មេធាវីការពារក្ដីនោះឡើយ។ ទោះបីជាយ៉ាងនេះក្ដី ស.ច.ស.អ ពិតជាបានបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ ប៉ុន្តែមិនបានដាក់ "កំណត់ត្រា" នៅក្នុងសំណុំរឿងទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីជាបានលើកឡើងនូវទឡ្ហីករណ៍ដែលចោទប្រកាន់ថា កំហុសអង្គច្បាប់របស់ ស.ច.ស.អ នៅក្នុងការកំណត់ទៅលើអនុស្សរណៈក៏ដោយ ក៏មេធាវីការពារក្ដីពុំបានពន្យល់នៅក្នុងបណ្ដឹងឧទ្ធរណ៍ថាតើកំហុសដែលបានចោទប្រកាន់នោះ ប្រសិនបើរកឃើញ នឹងមោឃភាពដីកាសម្រេចរបស់ ស.ច.ស .អ ដែលបដិសេធសំណើរបស់មេធាវីការពារក្ដីសុំដាក់ "កំណត់ត្រា" នៅក្នុងសំណុំរឿង ដោយរបៀបណា។

27. ហេតុដូច្នេះ ចៅក្រមដែលបានចុះហត្ថលេខាសន្និដ្ឋានថា នៅក្នុងបណ្ដឹងឧទ្ធរណ៍ត្រង់មូលដ្ឋានមួយនេះ មេធាវីការពារក្ដីពុំបានបង្ហាញរឿងក្ដីនេះទាំងមូលសម្រាប់ជាមូលដ្ឋានឲ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេចដែលត្រូវបានជំទាស់នោះទេ។

28. ចៅក្រមដែលបានចុះហត្ថលេខាច្រានចោល មូលដ្ឋានទីមួយនៃបណ្ដឹងឧទ្ធរណ៍នេះ ។

### ២. កំណត់ត្រាដែលបានធ្វើឡើងដោយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស

29. តាំងពីដំបូងមក ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ឃើញថា ខុសពីសាលាក្ដីអន្តរជាតិដែលការស៊ើបអង្កេតត្រូវបានធ្វើឡើងដោយភាគី[49] ការស៊ើបអង្កេតនៅ អ.វ.ត.ក ត្រូវបានធ្វើឡើងដោយមន្ត្រី*តុលាការ* អព្យាក្រឹត្យ ដូចជា ចៅក្រមស៊ើបអង្កេត[50] ដែលច្បាប់តម្រូវឲ្យ "ស៊ើបអង្កេត

[48] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៥។

[49] លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (តុលាការ ICTY) មាត្រា ១៨។ លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (តុលាការ ICTR) មាត្រា ១៥។ លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ (តុលាការ STL) មាត្រា ១១។ លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (តុលាការ ICC) មាត្រា ៥៤។

[50] កិច្ចព្រមព្រាងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការកាត់សេចក្ដីក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ

ដោយមិនលម្អៀង មិនថាភ័ស្តុតាងនោះដាក់បន្ទុក ឬ ដោះបន្ទុកនោះទេ”[51]។ ទោះបីជាក្នុងប្រព័ន្ធច្បាប់នានា ផ្សេងទៀត វិធានជាធរមានតម្រូវឱ្យ*ភាគី* ដាក់បង្ហាញព័ត៌មានជូនគ្នាទៅវិញទៅមកក៏ដោយ[52] ក៏នៅ អ.វ.ត.ក *ចៅក្រម* ស៊ើបអង្កេតមានឆន្ទានុសិទ្ធិធំធេងនៅក្នុងការសម្រេចថាតើកិច្ចស៊ើបសួរណាដែលមានប្រយោជន៍សម្រាប់ការស៊ើបអង្កេត ហើយថាតើភ័ស្តុតាងណាត្រូវដាក់បញ្ចូលក្នុងសំណុំរឿង[53]។ យើងចាំបាច់ត្រូវរម្លឹកថា នៅ អ.វ.ត.ក ភ័ស្តុតាងសម្រាប់ប្រើប្រាស់នៅពេលជំនុំជម្រះត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ដែលជាកំណត់ត្រានីតិវិធីតែមួយគត់ ហើយទោះបីជាវិធានអនុញ្ញាតឱ្យភាគីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទៅ ក.ស.ច.ស ក៏ដោយ ក៏គ្មានវិធានណាមួយបានផ្តល់សិទ្ធិផ្នែកនីតិវិធីក្នុងការស្នើសុំការដាក់បង្ហាញនោះទេ។ ហេតុដូច្នេះ ច្បាប់ និងការអនុវត្តពាក់ព័ន្ធនឹងការដាក់បង្ហាញនៅចំពោះមុខសាលាក្តីអន្តរជាតិទាំងនោះ ពុំអាចយកមកប្រដូចនឹងច្បាប់ និងការអនុវត្តពាក់ព័ន្ធនឹងការចូលរួមរបស់មេធាវីការពារក្តីនៅក្នុងការស៊ើបអង្កេត និងសិទ្ធិចូលពិនិត្យមើលសំណុំរឿងនៅ អ.វ.ត.ក បាននោះទេ។

30. ត្រង់ចំណុចនេះ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា សំណើរបស់មេធាវីការពារក្តីសុំដាក់បង្ហាញ “កិច្ចសន្ទនារវាងអ្នកស៊ើបអង្កេត សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលហួសពីសំណួរវាយតម្លៃ” របស់មេធាវីការពារក្តី ពុំមានមូលដ្ឋានឡើយ ព្រោះថា “កិច្ចសន្ទនាទាំងនេះគឺជា “ចម្លើយ””[54]។ ទោះបីជាវិធានជាធរមាននៅចំពោះមុខសាលាក្តីអន្តរជាតិចែងថា “ចម្លើយសាក្សី”

.ត.ក”) មាត្រា ៥(១)។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយរួមបញ្ចូលវិសោធនកម្មដែលបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (NS/RKM/1004/006) (“ច្បាប់ អ.វ.ត.ក”) មាត្រា ២៣ថ្មី។

[51] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(១) ច្បាប់ អ.វ.ត.ក មាត្រា ២៥ វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។

[52] វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY (វិធានស្តីពីនីតិវិធី និងភ័ស្តុតាង) ផ្នែកទីប្រាំ ជំពូក ៤ វិធាន ៦៦ ដល់ វិធាន ៧០។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTR ផ្នែកទីប្រាំ ជំពូក ៣ វិធាន ៦៦ ដល់ វិធាន ៧០។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ STL ផ្នែកទីប្រាំ ជំពូក ៧ វិធាន ១១០ ដល់ វិធាន ១២១។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ SCSL ផ្នែកទីប្រាំ ជំពូក ៣ វិធាន ៦៦ ដល់ វិធាន ៧០។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICC ជំពូក IV ផ្នែកទី II វិធាន ៧៦ ដល់ វិធាន ៨៤។

[53] វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

[54] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩ ។

ខ្លះ ត្រូវយកមកដាក់បង្ហាញក៏ដោយ[55] ក៏វិធាននេះពុំឃើញមាន ឬត្រូវបានយកមកអនុវត្តនៅក្នុងបរិបទគតិយុត្តិនៃ អ.វ.ត.ក នោះឡើយ។ ចៅក្រមដែលបានចុះហត្ថលេខាសូមរម្លឹកថា នៅ អ.វ.ត.ក មិនថាព័ត៌មានស្នើសុំពាក់ព័ន្ធ ឬ មិនពាក់ព័ន្ធនឹងចម្លើយសាក្សីនោះទេ លក្ខណវិនិច្ឆ័យតែមួយគត់ក្នុងការស្នើសុំបំពេញកិច្ចស៊ើបសួរដែលត្រូវបំពេញគឺ (១) លក្ខខណ្ឌស្តីពីភាពជាក់លាក់ និង (២) លក្ខខណ្ឌស្តីពីភាពពាក់ព័ន្ធបឋម[56]។ អង្គបុរេជំនុំជម្រះបានកំណត់ថា "បទប្បញ្ញត្តិវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ចែងមិនច្បាស់ថាតើវិធាននេះត្រូវយកមកអនុវត្តស្របគ្នានឹងវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងដែរឬទេ។ បើតាមវិធាន ៥៥(១០) នេះ ភាគីដែលដាក់សំណើត្រូវកំណត់ឱ្យច្បាស់នូវការស្នើសុំបំពេញកិច្ចស៊ើបសួរ និងរៀបរាប់មូលហេតុដែលភាគីស្នើសុំយល់ឃើញថា មានភាពចាំបាច់សម្រាប់ដឹកនាំការស៊ើបអង្កេត"[57]។ ម្យ៉ាងវិញទៀត ក្នុងករណីសំណើសុំបំពេញកិច្ចស៊ើបសួរក៏ផ្អែកលើភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង ត្រូវស៊ើបអង្កេតរកភស្តុតាងដោះបន្ទុកនោះ វាពុំគ្រប់គ្រាន់សម្រាប់មេធាវីការពារក្តីក្នុងការយោងតែលើឯកសារ "ពាក់ព័ន្ធ" និង "ចាំបាច់សម្រាប់មេធាវីការពារក្តី" ហើយត្រឹមតែអះអាងថា ឯកសារទាំងនេះមានភស្តុតាងដោះបន្ទុក ដោយពុំចាំបាច់ពន្យល់បន្ថែមថាតើឯកសារទាំងនេះអាច ឬមិនអាចបង្ហាញពីភាពគ្មានទោស ឬសម្រាលការទទួលខុសត្រូវបុគ្គលរបស់ជនត្រូវចោទនោះទេ[58]។

---

[55] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY និង ICTR វិធាន ៦៦(ក)(ii)។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ SCSL វិធាន ៦៦(ក)(i)។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ STL វិធាន ១១០(ក)(i)។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC វិធាន ៧៦(ក)។

[56] សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០២") (អ.ប.ជ ៦៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារទាំងឡាយពាក់ព័ន្ធនឹងសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន" ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D370/2/11 កថាខណ្ឌ ២២។

[57] សំណុំរឿង ០០២ (អ.ប.ជ ២៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D164/4/13 (សេចក្តីសម្រេចលើថតផ្ទុកឯកសាររួម) កថាខណ្ឌ ៤៤ និងលេខយោងជើងទំព័រ ៥៦។

[58] សំណុំរឿង ០០២ (អ.ប.ជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំរបស់លោក នួន ជា សុំឱ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស និងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើសុំបើកកិច្ចស៊ើបសួរពាក់ព័ន្ធនឹងរដ្ឋបរទេសចំពោះការទាត់ចោលសំណើសុំស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយលោក ខៀវ សំផន ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D315/1/5 កថាខណ្ឌ ២១។ សំណុំរឿង ០០២ (អ.ប.ជ ៤៩) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំរបស់លោក នួន ជា សុំឱ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋ

01454915



31. ចៅក្រមដែលបានចុះហត្ថលេខាកត់សម្គាល់ឃើញថា ពាក់ព័ន្ធនឹងឧបសម្ព័ន្ធ ខ នៃសំណើសុំលើកទីដប់ ស.ច.ស.អ បានដោះស្រាយរួចហើយលើសំណើសុំឈ្មោះបុគ្គល[59]។ ចំពោះសំណើសុំផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធ ខ សុំកំណត់ហេតុរបស់សាក្សីសក្ខានុពលដែលយោងតាមមេធាវីការពារក្ដីអាចមានភ័ស្តុតាងដោះបន្ទុកនោះ ចៅក្រមដែលបានចុះហត្ថលេខាសង្កេតឃើញថា នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ ស.ច.ស.អ ក៏បានបញ្ជាក់អំពីអត្ថិភាពនៃកំណត់ហេតុស្ដាប់ចម្លើយសាក្សីទាំងនេះនៅក្នុងសំណុំរឿងផងដែរ[60]។

32. ទាក់ទងនឹងឧបសម្ព័ន្ធ ក នៃសំណើសុំលើកទីដប់នេះ ចៅក្រមដែលបានចុះហត្ថលេខាបានកត់សម្គាល់ដំបូងបំផុតថា នៅក្នុងដីកាសម្រេចដែលត្រូវបានជំទាស់ ស.ច.ស.អ បានដោះស្រាយសំណើនីមួយៗរបស់មេធាវីការពារក្ដីសុំកំណត់ហេតុសាក្សីសក្ខានុពលដែលអាចមានភ័ស្តុតាងដោះបន្ទុក[61] ហើយបានសម្រេចលើសំណើសុំទាំងនេះដោយផ្អែកលើមូលដ្ឋាននានា រួមទាំង i) ដោយហេតុថា នៅពេលបញ្ចប់កិច្ចស៊ើបសួរ ស.ច.ស.អ មានបំណងដកការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅក្នុងតំបន់ ៤២[62] ii) ដោយហេតុថា យោងតាមហេតុផលដូចបានបង្ហាញយ៉ាងច្បាស់នោះ ស.ច.ស.អ ពុំយល់ស្របតាមសំណើសុំរបស់មេធាវីការពារក្ដីទេ[63] iii) ដោយ

---

បរទេស និងសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើសុំបើកកិច្ចស៊ើបសួរពាក់ព័ន្ធនឹងរដ្ឋបរទេស ចំពោះការទាត់ចោលសំណើសុំស្ដាប់ចម្លើយសាក្សីដែលធ្វើឡើងដោយលោក ខៀវ សំផន ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D315/2/2 កថាខណ្ឌ ២១។

[59] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៦៨ ដល់ កថាខណ្ឌ ៨១ *ដែលយោងលើ* ឧបសម្ព័ន្ធ ខ។

[60] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៧៤ កថាខណ្ឌ ៧៥ និងកថាខណ្ឌ ៧៧ *ដែលយោងលើ* ឧបសម្ព័ន្ធ ខ លេខរៀងទី ២ និងលេខរៀងទី ៣។

[61] *សូមមើល* សំណើសុំលើកទីដប់ កថាខណ្ឌ ៤០។

[62] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣២ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ៤) កថាខណ្ឌ ៤៧ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ២៣) កថាខណ្ឌ ៥៩ ដល់ កថាខណ្ឌ ៦០ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ៤៩) កថាខណ្ឌ ៦២ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ៥០)។

[63] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣២ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ៦) កថាខណ្ឌ ៤០ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ១២) កថាខណ្ឌ ៤៥ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ១៧) កថាខណ្ឌ ៥៥ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ៤៣) កថាខណ្ឌ ៦២ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ៥០) កថាខណ្ឌ ៦៤ ដល់ កថាខណ្ឌ ៦៥ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ៥២)។

ហេតុថា ស.ច.ស.អ បានស្តាប់ចម្លើយសាក្សីរូបនោះហើយ[64] និង iv) ដោយហេតុថា ស.ច.ស.អ កត់សម្គាល់ឃើញ និងបញ្ជាក់ថា នៅក្នុងការវាយតម្លៃរបស់គាត់ គាត់នឹងពិចារណាទៅលើព័ត៌មានដែលមានតម្លៃដោះបន្ទុក[65]។ ចំណុចទីពីរ ចៅក្រមដែលបានចុះហត្ថលេខាយល់ឃើញថា នៅក្នុងបណ្តឹងឧទ្ធរណ៍ ក្រៅពីលើកឡើង ទឡ្ហីករណ៍ដែលមានលក្ខណៈទូទៅ និងទាយស្មាន[66] មេធាវីការពារក្តីពុំតវ៉ាឱ្យបានជាក់លាក់លើផ្នែកផ្សេងៗនៃសេចក្តីសម្រេចរបស់ ស.ច.ស.អ ដែលបានលើកឡើងខាងលើនោះទេ។

33. សរុបសេចក្តីមក ចៅក្រមដែលបានចុះហត្ថលេខា ពុំយល់ឃើញថា ដីកាសម្រេចដែលត្រូវបានជំទាស់មានកំហុសដែលនាំឱ្យមានមោឃភាពនោះទេ។

34. ចៅក្រមដែលបានចុះហត្ថលេខាច្រានចោលមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍នេះ។

35. ហេតុដូច្នេះហើយ ចៅក្រមចុះហត្ថលេខាច្រានចោលបណ្តឹងឧទ្ធរណ៍នេះទាំងស្រុងតែម្តង។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ២៦ ខែមេសា ឆ្នាំ២០១៧**

**Olivier BEAUVALLET** **Kang Jin BAIK**

[64] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៤១ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ១៣) កថាខណ្ឌ ៦៧ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ៦៦)។

[65] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣៤ (*ដែលយោងលើ* ឧបសម្ព័ន្ធ ក លេខរៀងទី ៧)។

[66] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤០៖ “ព័ត៌មានដែលត្រូវបានស្នើសុំនៅក្នុងសំណើសុំលើកទឹកដប់ជាប់ពាក់ព័ន្ធជាពិសេសនឹងភ័ស្តុតាងគន្លឹះ ហើយការដាក់បង្ហាញគឺដើម្បីបញ្ជាក់ការពិតនៅក្នុងការស៊ើបអង្កេត ហើយ*អាច*នាំដល់ការបង្ហាញភ័ស្តុតាងដោះបន្ទុក”។